បានមិនលើសពី ១០០.០០០ រៀលទេ ប្រាក់សំណល់ត្រូវដាក់ជាចំណូល នៃថវិកាភ្នាម ។

**ប្រការ ៦.**- ទំនិញទាំងឡាយដែលបាននាំចូលមុនថ្ងៃអនុវត្តប្រកាសនេះដែលកំពុងសិចត នៅក្នុងឃ្លាំងនោះក៏ត្រូវទទួលបន្ទុកអនុវត្តដូចប្រកាសនេះផងដែរ ។

**ប្រការ ៧.**- បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨.**- ប្រកាសនេះអោយមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៦ តទៅ ។

ហត្ថលេខា និង ត្រា

**គាត ឈន់**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦

## ប្រកាស លេខ : ២៥៨ ប្រក.សហវ.គរ

## ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើទំនិញនាំចេញ និង នាំចូលតាមកុងតឺន័រ « CONTAINER » ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យគ្រប់គ្រងផែស្ងួតនិងឃ្លាំងដែលគ្រប់គ្រងដោយគយនិងទីលានបញ្ចេញទំនិញពីគយ និង រដ្ឋាករ

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤ / ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស.រកម ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញប្រកាសលេខ ១២៥ ប្រក.សហវ.គរ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៣១៨ ប្រក.សហវ.គរ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ០០៨ ប្រក.សហវ.គរ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងការងារចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១.**~ បណ្តាក្រុមហ៊ុន ឬ បុគ្គលដែលត្រូវយកកុងតឺនីទំនិញមកធ្វើការត្រួតពិនិត្យ និង ឬ បង់ពន្ធនៅភ្នំពេញទាំងអស់ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និង ត្រួតពិនិត្យដោយផ្ទាល់របស់ការិយាល័យគ្រប់គ្រងផែស្ងួត និង ឃ្លាំងដែលគ្រប់គ្រងដោយគយ និង ទីលានបញ្ចេញទំនិញពីគយនិងរដ្ឋាករ ។

**ប្រការ ២.**~ ទំនិញនាំចូលតាមកុងតឺនី ដែលអាចយកមកធ្វើការត្រួតពិនិត្យ និង ឬ បង់ពន្ធនៅភ្នំពេញបាន ចាំបាច់ ត្រូវមានលិខិតអនុញ្ញាតពីទីចាត់ការគយនិងរដ្ឋាករ ជាមុន ។

**ប្រការ ៣.**~ ក្រោយពីបានលិខិតអនុញ្ញាតពីទីចាត់ការគយនិងរដ្ឋាករ ក្រុមហ៊ុន ឬ បុគ្គលដែលជាម្ចាស់ទំនិញ ឬ ម្ចាស់ផែស្ងួត ឬ ម្ចាស់ឃ្លាំងដែលគ្រប់គ្រងដោយ ការិយាល័យគ្រប់គ្រងផែស្ងួត និងឃ្លាំងដែលគ្រប់គ្រងដោយគយ និង ទីលានបញ្ចេញទំនិញពីគយនិងរដ្ឋាករក្រៅពីផែស្ងួត ត្រូវកក់ប្រាក់ ពន្ធនៅការិយាល័យគ្រប់គ្រងផែស្ងួតនិងឃ្លាំងដែលគ្រប់គ្រងដោយគយ និង ទីលាន បញ្ចេញទំនិញពីគយនិងរដ្ឋាករ ព្រមទាំងត្រូវបំពេញប្រតិវេទន៍ឆ្លងកាត់នៅទីស្នាក់ការ គយនិងរដ្ឋាករ នាមាត់ច្រកនាំ

ចូលទំនិញចំនួន ០៥ «ប្រាំ» ច្បាប់ ដោយបញ្ជាក់ ច្បាស់អំពីមុខទំនិញ លេខកុងតឺន័រ និង លេខសៀល « SEAL » ។

**ប្រការ ៤.-** ការិយាល័យគ្រប់គ្រងផែស្ងួតនិងឃ្លាំងដែលគ្រប់គ្រងដោយគយនិងទីលានបញ្ចេញទំនិញពីគយនិងរដ្ឋាករ ត្រូវបញ្ជាក់អំពីមុខទំនិញ លេខកុងតឺន័រ និង លេខសៀល ដែលបានទទួលយកមកធ្វើការគ្រប់គ្រងនៅលើ ប្រតិវេទន៍ឆ្លងកាត់ទាំងនោះ បន្ទាប់មកទើបអាចធ្វើការត្រួតពិនិត្យ និង បង់ពន្ធបាន ក្រោយពេលដែលបណ្ដា ក្រុមហ៊ុន ឬ បុគ្គលទាំងនោះបានបំពេញប្រតិវេទន៍គយលំអិតរួចហើយ ។

**ប្រការ ៥.-** បណ្ដាក្រុមហ៊ុន ឬ បុគ្គល អាចបំពេញបែបបទនៅការិយាល័យគ្រប់គ្រងផែស្ងួតនិងឃ្លាំងដែលគ្រប់គ្រងដោយគយ និង ទីលានបញ្ចេញទំនិញពីគយនិងរដ្ឋាករ បានចំពោះមុខទំនិញផ្ទុកក្នុងកុងតឺន័រ ដើម្បីនាំចេញតាមបណ្ដា ច្រកនាំចេញនានា ។

**ប្រការ ៦.-** ចំពោះទំនិញដែលត្រួតពិនិត្យឃើញមានការខុសពីប្រវេទន៍គយលំអិតនោះ បណ្ដាក្រុមហ៊ុន ឬ បុគ្គល ឬ អ្នកតំណាង នឹងត្រូវទទួលទោសតាមច្បាប់ស្ដីពីពន្ធលើ ទំនិញនាំចេញ - នាំចូល ។

**ប្រការ ៧.-** ទីចាត់ការគយនិងរដ្ឋាករ មានភារកិច្ចណែនាំលំអិតអំពីការប្រើប្រាស់ប្រតិវេទន៍ឆ្លងកាត់ ។

**ប្រការ ៨.-** ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩.-** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

**គាត ឈន់**

* * *